ឯកសាបន្ថែមប្រចាំតំបន់
ដល់កំណត់ត្រារបស់អេកូ

# កំណត់ត្រារបស់អេកូអាស៊ី

កែសំរួលដោយលោកអាប្រាម ប៊ិកស្លឺ និងរេបេខា ហ្វារូហ្វាន្ទ ខែតុលា២០១៣ លេខ១៨

## ការស្វាគមន៍ប្រធានថ្មីរបស់មជ្ឈមណ្ឌលជះឥទ្ធិពលនៅតំបន់អាស៊ី

ដោយ អាប្រាម ប៊ិស្លឺ

---

ក្នុងនាមជាប្រធានថ្មីនៃមជ្ឈមណ្ឌលឥទ្ធិពលអេកូអាស៊ី ខ្ញុំសូមយកឧកាសនេះក្នុងការស្វាគមន៍ អ្នកទាំងអស់គ្នា សមាជិកបណ្តាញរបស់យើង។ខ្ញុំសូមអរគុណសំរាប់ជាផ្នែកនៃបណ្តាញរបស់យើង ដែលបន្តរីកដុះដាលជាសកលហើយដែលមានជាព័ត៌មានសំរាប់អ្នកអនុវត្តន៍ផ្នែកអភិវឌ្ឍន៍និងកសិករជុំវិញពិភពលោក។ទូទាំងប្រវត្តិសាស្រ្តរបស់អេកូ យើងបានធ្វើការជាអស្ចារ្យដើម្បីប្រមូលដំណោះស្រាយដែលទាក់ទងទៅនឹងភាពអត់ឃ្លាន ពីជុំវិញពិភពលោកហើយចែកពួកវាជាមួយបណ្តាញរបស់យើង។

ដំណោះស្រាយនេះផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលមាននិរន្តរភាព រុក្ខជាតិអាហារូបត្ថម្ភ ហើយនិងបច្ចេកវិទ្យាដែលសមស្រប ពួកវាត្រូវបានធ្វើតេស្តយ៉ាងល្អ និងបានបង្ហាញថាមានជោគជ័យម្តងហើយម្តងទៀត។ បណ្តាញថ្នាក់ក្រោមរបស់អេកូ បានបង្ហាញការងារមជ្ឈមណ្ឌលឥទ្ធិពលក្នុងតំបន់របស់វា ទូទាំងពិភពលោក គឺជួយដល់អ្នកដែលមានធនធានតិចនិងអ្នកអត់ឃ្លាន ដោយអាចអោយគេចិញ្ចឹមខ្លួនបានហើយបង្កើនជីវភាពរស់នៅរបស់គេតាមរយៈដំណោះស្រាយក្នុងតំបន់។ យើងមានកិត្តិយលក្នុងការចូលរួមក្នុងការងារដែលដំណើរការនេះ ហើយធ្វើការជាមួយអ្នក ជាសមាជិករបស់យើង ជាផ្នែកមួយនៃក្រុមរបស់អេកូ។ ការងារសំខាន់ជាច្រើនដែលអេកូជះឥទ្ធិពលនៅអាស៊ីដឹងគុណគឺការលះបង់របស់រិកនិងអេឡេនបីណែតធ៌។

បន្ទាប់ពីអាជីព១៨ឆ្នាំមកនៅក្នុងការអភិវឌ្ឍន៍សហគមន៍នៅក្នុងប្រទេសថៃដោយធ្វើការជាមួយនឹងគំរោងអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយរបស់អ្នកតំបន់ខ្ពង់រាប (UHDP) រិកនិងអេឡេនបីណែតបានទទួលយកតួនាទីភាពដឹកនាំដែលនាំផ្លូវដំបូងរបស់មជ្ឈមណ្ឌលជះឥទ្ធិពលអេកូនៅអាស៊ីក្នុងឆ្នាំ២០០៩។ ៤ឆ្នាំចុងក្រោយបានឃើញភាពលូតលាស់ដ៏ច្រើនក្នុងធនធាននិងសេវាកម្មដែលបានផ្តល់ជូនទៅដល់អ្នកដែលមានធនធានតិចតួចក្នុងតំបន់អេកូទាំងមូល។ដូចអ្នកទាំងអស់បានដឹងហើយថា ឆ្នាំទៅមិញ ជាមួយនឹងការអធិស្ថាន និងការដឹកនាំរបស់ព្រះជាម្ចាស់ រិកនិងអេឡេនបានទទួលយកតំណែងមួយដឹកនាំផ្នែក

កសិកម្មរបស់អេកូនៅហ្វតមេយ័រ ហ្វ្លរីដា។ គាត់ចាប់ផ្តើមការងារថ្មីនេះជាមួយនៅខែកក្កដា ២០១៣។ ជាមួយនឹងវិញ្ញាណនៃការដឹងគុណសំរាប់ការងារដ៏អស្ចារ្យមិនគួរអោយជឿរបស់បីណែតនៅមជ្ឈមណ្ឌលជះឥទ្ធិពលរបស់អេកូនៅអាស៊ីនេះ ខ្ញុំសូមនែនាំខ្លួនខ្ញុំ។ ខ្ញុំក៏សូមយកឧកាសនេះដើម្បីមើលជាមួយអ្នក នូវអ្វីដែលត្រូវផ្តល់ជូននៅអនាគត។

ក្នុងវិធីជាច្រើន ខ្ញុំសូមយកតួនាទីជាអ្នកដឹកនាំនេះ ពីប្រព័ន្ធប្រកបដោយថាមពលនិងយុទ្ធសាស្ត្រអេកូឡូស៊ី ដោយបានធ្វើការក្នុងការអភិវឌ្ឍន៍និងការបង្រៀនផ្នែកកសិកម្មរយះពេល៩ឆ្នាំ។ ខ្ញុំបានបញ្ចប់សញ្ញាបត្របីអេស ពីសកលវិទ្យាល័យថៃលីផ្នែកវិទ្យាសាស្ត្របរិស្ថាន ហើយក៏សំរាកធ្វើដំណើរទូរទាំងពិភពលោកហើយរៀនពីវប្បធម៌និងប្រព័ន្ធ។ ផ្នែកនៃពេលវេលារបស់ខ្ញុំបានចំណាយជាមួយនឹងអេកូនៅហ្វ្លរីដា ដែលខ្ញុំជាអ្នកមនុស្សដំបូងដែលបានបង្ហាញភាពអស្ចារ្យនៃដំណាំគ្របដី ការបង្កើនគុណភាពដី បច្ចេកវិទ្យាសមស្រប ហើយនិងធនាគាគ្រាប់ពូជ ខ្ញុំក៏បានចូលរួមសន្និបាទប្រចាំឆ្នាំរបស់អេកូ។ ក្នុងលក្ខណះពិសេសនេះខ្ញុំបានចាប់ចិត្តជាមួយនឹងសក្តានុពលនៃកសិកម្មតំបន់ត្រូពិក ដែលគេបានអនុវត្តន៍ក្នុងវិធីដែលមាននិរន្តរភាព ដើម្បីផ្តលជាប្រយោជន៍និងជីវភាពរស់នៅដល់ជនក្រីក្រ។

ការឃ្លាននូវការសិក្សាអប់រំបន្ថែម ខ្ញុំក៏បានបញ្ចប់ការសិក្សា អិមអេស និងភីអេចឌី ផ្នែកវិទ្យាសាស្ត្របិរស្ថាន នៅសកលវិទ្យាល័យរដ្ឋអិលីណយ នៅយុទ្ធនាការអ៊ូបាណា។ គំរោងរបស់ខ្ញុំទាំងពីរផ្តោតលើ អេកូឡូស៊ីនិងនិរន្តរភាពនៃដំណាំគ្រប់ដីដើម្បីបង្កើនគុណភាពដី កាត់បន្ថយសត្វចង្រៃនិងជំងឺ ហើយបង្កើនទិន្នផល។ ខ្ញុំកើតមានការស្រឡាញ់ភាពចំរុះនិងសម្រស់នៃប្រព័ន្ធអេកូកសិកម្ម (ដែលជាការសិក្សាពីអេកូឡូស៊ីនៃប្រព័ន្ធកសិកម្មចំរុះនៃជីវិតរុក្ខជាតិ ជីវិតសត្វ ជីវិតដី ទឹក អាហាររូបត្ថម្ភនិង រដ្ឋថាមពល)។

ប្រពន្ធរបស់ខ្ញុំហើយនិងខ្ញុំបានមករស់នៅឈៀងម៉ៃក្នុងឆ្នាំ ២០០៩ ដែលខ្ញុំបានចាប់ផ្តើមបង្រៀនប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាពដល់សិស្សនិស្សិតមិនទានបញ្ចប់ការសិក្សាជនជាតិអាមេរិកាំង តាមរយះវិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ដែលមាននិរន្តរភាពជាអន្តរជាតិ (ISDSI) ខណះពេលនៅវិទ្យាស្ថាននេះខ្ញុំក៏បានបង្រៀនផងដែរពីការបញ្ចូលសិទ្ធិមនុស្សនិងបរិស្ថានតាមរយះប្រព័ន្ធអេកូឡូស៊ីទឹកទន្លេ រាប់ទាំងផលប៉ះពាល់ដែលមកពីការបំផ្លាញបរិស្ថាន អាចកើតមានសុខមាលភាពមនុស្ស។ អំឡុងពេល៤ឆ្នាំនេះនៃការបង្រៀន ខ្ញុំមានអភ័យឯកសិទ្ធិទទួលបាននូវការស្គាលរិក។

ខ្ញុំបានទទួលព្រះពរផងដែរ ដោយឧកាសាការងារជាមួយអេកូអាស៊ីជាទីប្រឹក្សាស្រាវជ្រាវនិងធនាគាគ្រាប់ពូជ។ ការទាក់ទងរបស់ខ្ញុំរាប់ទាំង ការស្រាវជ្រាវការអនុវត្តន៍ល្អបំផុត សំរាប់ការទុកដាក់គ្រាប់ពូជ

ការស្រាវជ្រាវការអនុវត្តន៍ការផលិត សំរាប់ធនាគារគ្រាប់ពូជ មើលទៅលើគំរោងការពង្រីកចេក ការស្រាវជ្រាវពីប្រពន្ធគ្រាប់ពូជកសិករ ការជួយទទួលធ្វើសិក្ខាសាលានៅឥណ្ឌានិរតី ភូមា ឈៀងម៉ៃ និងនៅភីលីពីន។ឆ្លើយតបទៅនឹងសំណូមពរបច្ចេកទេស និងការនិពន្ធព័ត៌មានអេកូអាស៊ី។ ខ្ញុំសូមអរគុណសំរាប់ឧកាលពីមុន ហើយសប្បាយចិត្តដែលបានធ្វើការនៅក្នុងសមត្ថភាពថ្មីនេះជាមួយអេកូអាស៊ី និងសមាជិកបណ្តាញរបស់ខ្លួន។

ដោយការដែលយើងធ្វើដំណើររួមគ្នានៅលើមាគានេះ ខ្ញុំសូមសំដែងការសប្បាយចិត្តដែលឃើញថាព្រះនឹងប្រើប្រាស់ការិយាល័យនេះហើយនិងបុគ្គលិកអេកូអោយបន្តរការផ្តល់អំណាចអ្នកធ្វើការងារពីជុំវិញពិភពលោកអោយបំពេញបាននូវតម្រូវការកាន់តែប្រសើរឡើងដល់អ្នកមានធនធានតិចតួចនិងអ្នកអត់ឃ្លាន បង្កើនជីវភាពរស់នៅរបស់ពួកគេនិងប្រទានពរជីវិត្តរបស់គេ។ ខ្ញុំសូមធានាថា យើងផ្តោតការយកចិត្តទុកដាក់របស់យើងទៅលើតំបន់ពិសេសមួយចំនួនក្នុងឆ្នាំជិតមកដល់នេះ។ ដោយយើងជាដៃគូជាមួយគ្នា ខ្ញុំសូមអញ្ជើញអ្នកអោយជួយយើងបំពេញគោលដៅដែលមានដូចខាងក្រោមនេះ

ការស្រាវជ្រាវបន្ថែមស្តីពីការអនុវត្តន៍ពីបច្ចេកទេសថៃរក្សាគ្រាប់ពូជកំរិតភូមិ ដើម្បីជួយកសិករខ្នាតតូចអោយរក្សាគ្រាប់ពូជរបស់ខ្លួនអោយមានជាជីវចំរុះនិងកាត់បន្ថយចំណាយរបស់គេ។

បន្តរការទំនាក់ទំនងជាមួយសហគ្រិនគ្រាប់ពូជកសិករក្នុងតំបន់ដើម្បីបំពេញការចែកចាយគ្រាប់ពូជអេកូដែលមានការកើនឡើងហើយនិងផ្តល់ដល់កសិករនូវតំលៃសមរម្យសំរាប់ការផលិកគ្រាប់ពូជសំរាប់ធនាគាគ្រាប់ពូជអេកូអាស៊ី

ទាក់ទងជាមួយអ្នកធ្វើការអភិវឌ្ឍន៍អោយកាន់តែអស្ចារ្យ អង្គការ និងកសិករនៅឥណ្ឌា អាស៊ីកណ្តាលម៉ាឡេស៊ី ឥណ្ឌូនេស៊ី ចិនខាងត្បូង

បន្តរការសម្របសម្រួលសិក្ខាសាលាក្នុងតំបន់នៅប្រទេសដែលនៅជុំវិញជាជំរើសទាក់ទងដែលមានតំលៃថោកសំរាប់អ្នកធ្វើការថ្នាក់ជាតិនិងកសិករដើម្បីចូលរួមជាមួយព្រឹត្តិការណ៍របស់អេកូ

បង្កើនការត្រួតពិនិត្យនិងវាយតំលៃនៃសេវាកម្មរបស់អេកូអាស៊ីដោយសមាជិកបណ្តាញរបស់យើងដើម្បីជាប្រយោជន៍ដល់ឥទ្ធិលដល់កសិករខ្នាតតូចរបស់យើង

បង្កើនការវាយតំលៃនៃការបញ្ជារទិញគ្រាប់ពូជផ្សេងៗនៅបរិបទអាស៊ី។ផ្តួចផ្តើមអោយមានការប្រើប្រាស់ www.ECHOCommunity.org ជាឧបករណ៍ពង្រីកសំរាប់កសិករ អ្នកធ្វើការអភិវឌ្ឍន៍និងអង្គការ

បង្កើនការទាក់ទងហើយនិងសមត្ថភាពសំរាប់ ការបំពាក់ peri-urban និងតាមជាយក្រុងសំរាប់ការដាំអាហារ

បង្កើនការខិតខំដើម្បីបញ្ចូលវិន័យនៃអាហាររូបត្ថម្ភនិងកសិកម្មនៅកំរិតថ្នាក់គ្រួសារ។ ខ្ញុំសូមរងចាំធ្វើការជាមួយអ្នកនិងទទួលស្គាល់អ្នកថែមទៀតនៅក្នុងឆ្នាំនិងមកដល់។ សូមចែករំលែកមតិត្រឡប់របស់អ្នកព្រោះយើងធ្វើការងារនេះរួមគ្នា ហើយតស៊ូកសាងបណ្តាញទៅជាអ្វីមួយដែលមានថាមពល ដែលមានទំនាក់ទំនង មានអំណាច និងសមស្របសំរាប់តម្រូវការរបស់អ្នក។ សូមមានអារម្មណ៍ដោយរីករាយមកមើលការិយាល័យរបស់យើងនៅឈៀងម៉ៃ សូមអីម៉ែលមកខ្ញុំ abicksler@echonet.org or call me at +66-53-304-028. សូមព្រះប្រទានពរអ្នកនៅក្នុងការងាររបស់អ្នកនៃការនាំយកនៅដំណោះស្រាយសមស្របសំរាប់អ្នកក្រីក្រ។

ការស្វាគមន៍ពីប្រធានថ្មីរបស់អេកូអាស៊ីជះឥទ្ធិពលនៅតំបន់អាស៊ី ដោយលោក អាប្រាម ប៊ិកស្លឺ។

ដាក់ចូលទៅក្នុងអេកូ អេអិន១ ការស្វាគមន៍អីប្រធានថ្មីរបស់អេកូនៅតំបន់អាស៊ី ២ យុទ្ធសាស្ត្រតាមបែបចូលរួម ការបង្ហាញពីបទពិសោធន៍ ការបន្ថែមធនាគារគ្រាប់ពូជថ្មី សន្និបាទការអភិវឌ្ឍន៍សហគមន៍ និងកសិកម្មរបស់អេកូ

មជ្ឈមណ្ឌលជះឥទ្ធិពលអេកូអាស៊ីប្រតិបត្តិការក្រោម អេកូ ជាអង្គការគ្រីស្ទានមិនរកប្រាក់ចំណេញ ដែលជួយអ្នក ជួយអ្នកក្រអោយផលិតម្ហូបអាហារនៅក្នុងពិភពលោកកំពុងអភិវឌ្ឍន៍។

ECHO Asia Impact Center PO Box 64 Chiang Mai 50000 Thailand echoasia@echonet.org

www.ECHOcommunity.org

---

# យុទ្ធសាស្ត្រតាមបែបចូលរួម ការបង្ហាញពីបទពិសោធន៍

## ដោយ ដូក្លាស ប្រេស៊ី

*កំណត់ត្រារបស់អ្នកនិពន្ធ :ដូក្លាស ប្រេស៊ី គឺវាគ្មិនមួយរូបនៅឯសន្និបាទស្តីពីកសិកម្មនិងការអភិវឌ្ឍន៍របស់អេកូអាស៊ី ដែលប្រារព្វធ្វើឡើងនៅឈៀងម៉ៃពីថ្ងៃទី១ដល់ទី៥ខែតុលា។ វេជ្ជ ដូក្លាស គឺជាទីប្រឹក្សាផ្នែកនរវិទ្យាជាន់ ខ្ពស់ របស់អេសអាយអិលអន្តរជាតិ។ គាត់រស់នៅប្រទេសថៃ ជាកន្លែងដែលគាត់បំរើការជាអ្នកសម្របសម្រួលនរវិទ្យាអោយក្រុមអាស៊ីអាគ្នេយ៍នៅតំបន់ខ្ពង់រាបនិងបង្រៀន នរវិទ្យាវប្បធម៌នៅសកលវិទ្យាប៉ាយ៉ាប។ ពីដើមគាត់ធ្វើការក្នុងសាខាអេសអាយអិលនៅម៉ាលេស៊ីនិងហ្វីលីពីន។ លោកដូ មានសញ្ញាបត្រភីអេចឌីអេកូឡូស៊ីអន្តរវិន័យ។(ផ្តោតទៅលើ នរវិទ្យា) ពីសកលវិទ្យាល័យរដ្ឋហ្វ្លរីដា និងអិមអេសផ្នែកក្សេត្រសាស្ត្រពីសកលវិទ្យាល័យហ្វ្លរីដា និងប៊ីអេស ផ្នែកក្សេត្រសាស្ត្រពីសកលវិទ្យាល័យអេនិងអិមរដ្ឋតេចសាស។*

### សេចក្តីនែនាំ

វិធីសាស្ត្រតាមបែបចូលរួម ក្នុងការអភិវឌ្ឍន៍សហគមន៍ជាដំបូងកើតឡើងនៅឆ្នាំ ១៩៧០ ហើយការងារដែលគេធ្វើបានបន្តជាប្រយោជន៍ដើម្បីបន្តក្នុងចំណោមអ្នកអនុវត្តន៍ ជាពិសេសក្នុងឆ្នាំថ្មីៗនេះ។ អ្នកអនុវត្តន៍ជាច្រើនយល់ស្របថាការទទួលយកដ៏លូតលាស់នេះគឺជារឿងដ៏ល្អមួយ ព្រោះវាបានធ្វើអោយយើងយកចិត្តទុកដាក់ទៅលើវិធីដែលយើងចូលរួមជាមួយសហគមន៍ដែលយើងចង់ជួយ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមអញ្ជើញយើងមើលទៅលើវិធីសាស្ត្រដើម្បីពិចារណាអីដែលខ្ញុំនិងហៅថា យុទ្ធសាស្ត្រតាមបែបចូលរួម- ទស្សនះវិទ្យា គោលដៅ និងការសន្មត់ដែលអាចអោយយើងធ្វើការតាមបែបចូលរួមដ៏ល្អប្រពៃជាមួយសហគមន៍។

យុទ្ធសាស្ត្រតាមបែបចូលរួមនេះគឺមិនមែនជាបញ្ហាផ្នែកវីធីសាស្ត្រតាមការគិតនោះឡើយ ការស្តាប់និងការគោរពមនុស្សនៅសហគមន៍ទើបជាបញ្ហា ការលើកទឹកចិត្តពួកគេអោយទទួលបានគោលដៅ ផ្តល់វគ្គបណ្តុះបណ្តាល ការបង្រៀន និងការជួយ តែមិនត្រូវគ្រប់គ្រងដំណើរការឡើយ។ ភីអាអេ ភីអិលអេ អេប៊ីស៊ីឌីអី ជីអាអេអេភី អេអាយ និងការសង្ខេបមួយចំនួនទៀតគឺជាវិធីសាស្ត្រសំរាប់ធ្វើយុទ្ធសាស្ត្រតាមបែបចុលរួមនេះ។តែពួកវាគ្រាន់តែជាឧបករណ៍តែប៉ុណ្ណោះ។ ចូរពិចារណាទៅលើជាងចំលាក់ថ្មនិងឈើ គាត់ត្រូវការឧបករណ៍ទាំងនេះ តែគាត់លើសជាងអ្នកបច្ចេកទេសទៅទៀត។

វិចិត្រករគ្រប់ប្រភេទត្រូវធ្វើការជាមួយនឹងចរិកលក្ខណៈនៃរូបអារក្សរបស់គាត់ ជាជាងតទល់ជាមួយនិងពួកវា។ ចំលាក់ឈើសំឡឹងមើលសាច់និងទ្រង់ទ្រាយនៃបំណែកឈើដែលគាត់នឹងប្រើប្រាស់។ គាត់ពិចារណាថាវាងាយស្រួលកាត់និងពុះវាប៉ុន្មា ថាតើវាជាឈើធម្មតាឬឈើរឹងក ហើយថាតើវាគួរត្រូវដាក់ប្រេងឬក្រមួនឬខាត់លាបស៊ីលេចឬអត់។ នេះជាអ្វីដែលអ្នកវិចិត្រករធ្វើនៅពេលដែលធ្វើការជាមួយនឹងរូបរាងដែលអត់មានចលនានេះ-វាកាន់តែមានភាពស្មុគស្មាញនៅពេលដែលគាត់ធ្វើការជាមួយនឹងរបស់ដែលនៅមានជីវិត្ត អ្នកដាំដើមឈើតឿត្រូវតែពិចារណាថាតើដើមឈើគាត់ជ្រើសរើសលូសលាស់ដោយរបៀបណា។

ហើយអ្នកបង្ហាតសេះប្រណាំងពូជសុទ្ធ ត្រូវតែយល់ច្បាស់ថាតើសេះនេះនឹងរបស់ដោយរបៀបណា លើសពីនេះទៅទៀត តើវាគិតរបៀបណា។ ពេលយើងនៅក្នុងទីកន្លែងនៃការអភិវឌ្ឍន៍សហគមន៍ ធ្វើការជាមួយមនុស្ស និងជាមួយក្រុមមនុស្ស យើនឹងប្រឈមមុខនឹងកំរិតកាន់តែខ្លាំងឡើងនៅភាពសាំញ៉ាំ ភ្នាក់ងារផ្លាស់ប្តូមិនអាចចូលទៅក្នុងផែនការដែលបានកំណត់ទុកឡើយពីអ្វីដែលគាត់អោយសហគមន៍ទៅជាអ្វីនោះ។គាត់ត្រូវតែធ្វើការជាមួយសហគមន៍ ការទទួលស្គាល់ថា ពួកគេជាមនុស្សតែមួយដែលនឹងរស់នៅជាមួយផលវិបាកទោះជាការផ្លាស់ប្តូរកើតឡើងក៏ដោយ ហើយ ថាពួកគេជាអ្នកដែលជាម្ចាស់សិទ្ធនៃសហគមន៍របស់គេ។

នៅពេលជាមួយគ្នានេះដែរ ភ្នាក់ងារផ្លាស់ប្តូអាចមានតួនាទីពិសេសក្នុងការជួយសហគមន៍អោយទទួលបានការផ្លាស់ប្តូរជាវិជ្ជមាន។ ខណៈដែលសមាជិករបស់សហគមន៍ ដឹងពីចំនួនដ៏លើសលប់ពីខ្លួនឯងនិងស្ថានភាពរបស់គេដែលអ្នកក្រៅ មិនអាចដឹងបាន អ្នកខាងក្រៅអាចមានចំណេះដឹងនិងជំនាញដែលសហគមន៍ចង់បានដើម្បីទទួលបានឬក៏ ប្រើប្រាស់សំរាប់ភាពប្រសើរឡើងរបស់គេផ្ទាល់។

ល្បិចនេះគឺការបង្កើតទំនាក់សំរាប់ការគោរពទាំងសងខាង។ ចូរពិចារណាទៅលើគ្រូបង្រៀន គ្រូអាចមិនយកចិត្តទុកដាក់ជាមួយនិងចំណាប់អារម្មសិស្ស លទ្ធភាពធម្មជាតិ និងការងក់ក្បាលតាមបែបធម្មជាតិក្នុងស្ទីលរៀនសូត្រ ដោយធ្វើថាគាត់ដឹងច្បាស់ពីអ្វីល្អបំផុតសំរាប់សិស្ស។ ឬក៏គ្រូអាចធ្វើការជាមួយសិស្ស ជួយពួកគេអោយរៀនដោយយើងទៅលើចំណាប់អារម្មណ៍របស់គេនិងទំនោរធម្មជាតិរបស់គេខណៈពេលដែលទទួលស្គាល់ថាគាត់ដឹងអ្វីដែលពួកគេចង់ដឹងនិងអាចធ្វើបាន។ដូចជាវិចិត្រករនិងគ្រូអញ្ចឹង ជាភ្នាក់ងារធ្វើការផ្លាស់ប្តូដ៏មានជោគជ័យជាមួយសហគមន៍។

## ឧទាហរណ៍ពីបទពិសោធន៍

ដូច្នេះតើយុទ្ធសាស្រ្តតាមបែបចូលរួមដំណើរការយ៉ាងដូចម្តេចពេលគេធ្វើការជាមួយក្រុម ជាមួយសហគមន៍? ខ្ញុំសូមធ្វើការបង្ហាញរឿងនេះពីបទពិសោធន៍របស់ខ្ញុំក្នុងរយះពេលធ្វើការជាង១៩ឆ្នាំជាមួយមនុស្សក្កូតាបាតូ ម៉ាន្ទូបូ នៅភីលីពីន។




## ដំណាក់កាលទី១ ធ្វើតាមគំនិតដ៏ល្អបំផុតរបស់យើងផ្ទាល់ខ្លួន

អេសអាយអិល បានចាប់ផ្តើមធ្វើការជាមួយម៉ាណូបូក្នុងឆ្នាំ ១៩៥៤ ដោយផ្តោតទៅលើជាចំបងលើភាសា ការបកប្រែ និងអក្ខរកម្ម។ ក្នុងឆ្នាំនោះដែរប្រពន្ធរបស់ខ្ញុំ មេគ និងខ្ញុំបានចាប់ផ្តើមការងារជាមួយក្រុមម៉ាណូបូ ក្នុងឆ្នាំ១៩៨៣ ការចូលរួមជាមួយនឹងការបកប្រែនិងអក្ខរកម្មបានហុចលទ្ធផលមួយ




ប្រកបដោយការរីកចំរើននៅក្នុងគ្រីស្ទាននិងអ្នកអានមនុស្សពេញវ័យមួយចំនួនធំ។

ការផ្តោតរបស់យើងគឺ ការអភិវឌ្ឍន៍សហាគមន៍ ឧទាហរណ៍ ការជួយសហាគមន៍អោយធ្វើការជាមួយគ្នា សំរាប់ប្រយោជន៍ទៅវិញទៅមកក្នុងគ្រប់វិស័យនៃជីវិត ដូចជា ខាងព្រលឹងវិញ្ញាណ សេដ្ឋកិច្ច រាងកាយ



*ពីលើដល់ក្រោម (១) គ្រួសារទាំងនេះពីដើមនៅឯកោ ហើយភូមិនេះនៅតូច (២) ដង់ស៊ីតេប្រជាជនទាប ធ្វើកសិកម្មពនេចរ តាមការអនុវត្តជាក់ស្តែងនិងមាននិរន្តរភាព (៣) ការហូរចូលរបស់អ្នកតាំងទីលំនៅថ្មីបានបង្ខំម៉ាណូបូអោយសម្របខ្លួនតាមកសិកម្មតាមដំណើរ។*

និងនយោបាយ (ហើយនិងវិស័យផ្សេងទៀតដែលបានមើលរំលងក្នុងនិយមន័យនេះ)។ យើងបានចាប់ផ្តើមការងារយើងក្នុងចំណោមក្រុមម៉ាណូបូ ដោយការបង្រៀនបច្ចេកទេសដែលអ្នកដទៃបាននិយាយថាបានជួយក្នុងការបំពេញតម្រូវការតាមដែលយើងអង្កេតមើលឃើញ។យើងដឹងថាម៉ាណូបូនេះបាន អនុវត្តន៍កសិកម្មចំការ វីធីមួយដែលមាននិរន្តរភាពនិងទទួលខុសត្រូវផ្នែកអេកូឡូស៊ី(សានឆេស

1976:379),តែមានការប្រឈមនឹងការកើនឡើងនៃសំពាធនៃការធ្វើកសិកម្មតិចតួចដើម្បីរក្សាដីកុំអោយបាត់បង់អោយទៅអ្នមកតាំងទីលំនៅនៅភីលីពីន។

ជាលទ្ធផល ពួកគេត្រូវការការអភិវឌ្ឍន៍វិធីសាស្ត្រថ្មីមួយនៃកសិកម្មប្រកបដោយនិរន្តរភាពសំរាប់ដីភ្នំជំរាលជាកន្លែងដែលែករស់នៅ ហើយនិងការអនុវត្តន៍ផ្នែកសុខភាពដែលសមរម្យសំរាប់សហគមន៍ជាអចិន្ត្រៃ ដូច្នេះយើងបានបង្រៀនវិធីសាស្ត្រទាំងនេះដែលទាក់ទងនឹងតម្រូវការថ្មីរបស់គេ។ មួយក្នុងងចំណោមវិធីទាំងនេះ គឺជាបច្ចេកវិទ្យាដីកសិកម្មជំរាល (SALT) ដែលជាវិធីសាស្ត្រកសិកម្មមួយ ដែលគេដាំដើមឈើ រុក្ខជាតិដែលមានជាតិអាសូតក្នុងជួរជិតគ្នាតាមជំរាល ដោយទុកកន្លែងរវាងជួយនៃដំណាំដែលមានរយះពេលខ្លីក្នុងការប្រមូលផលដូចជា ពោត សណ្តែក ដំឡូងមី និងសណ្តែកដី។ ស្លឹកវាក្លាយជាជី ខណះដែលជួរនៃដើមឈើបានការពារការច្រោះដីមិនអោយខូច។

យុទ្ធសាស្ត្រនេះបានបង្ហាញថាមានផលទៅលើដីចោទនៅប្រទេសភីលីពីន។ បច្ចេកទេសមួយទៀតគឺការធ្វើសួនដំណាំ ដើម្បីបន្លែមបន្លែដោយពីដើមគេប្រមូលបានពីដីចំការរបស់គេ តែពេលនេះវាកាន់តែ ឆ្ងាយពីផ្ទះរបស់គេព្រោះអ្នកមកតាំងទីលំនៅថ្មីបានយកដីនៅជិតភូមិ។ ជាចុងក្រោយ មេគជាមួយនឹង លីអូនីតា គិល អានអាប៉ាង និងមេលីតា បាវ៉ាន់ ពីសមាគមអ្នកបកប្រែនៅប្រទេសភីលីពីនក៏បានផ្សព្វផ្សាយការសាងសង់និងការប្រើប្រាស់បង្គន់ដើម្បីការពារជំងឺរីករាកដាលដោយការប៉ះពាល់ជាមួយលាមកមនុស្ស។ ការចំលងជំងឺនេះគឺជាបញ្ហាតែងតែរីករាលដាល ព្រោះមនុស្សពេលនេះរស់នៅក្នុងភូមិជាជាងរស់នៅតែឯង។

បច្ចេកទេសទាំងនេះបានបំពេញតម្រូវការដែលជាភស្តុតាងជាក់ស្តែងដល់ទាំងអ្នកម៉ាណូបូនិងអ្នកខាងក្រៅដូចជាយើង តែជាការក្រលេកទៅក្រោយវិញពួកវាមិនមែនជាតម្រូវការបំផុតនោះឡើយ។ តែទោះជាការខិតខំរបស់យើងមិនបាន អេះចំកន្លែងរមាស់របស់គេក៏ដោយ ក៏វាបានជួយបង្កើតសមត្ថភាពនិងការព្រួយបារម្មណ៍របស់យើងសំរាប់អ្នកម៉ាណូបូដែរ។ វាជាជំហានការងារដែលស្របច្បាប់ហើយជាធម្មតាជាការចាំបាច់ ក្នុងការផ្លាស់ប្តូរការងាររបស់អ្នកធ្វើការសហគមន៍។ មនុស្សត្រូវការឃើញថា អ្នកយកខ្វល់ខ្វាយចំពោះពួកគេហើយថាអ្នកអាចធ្វើការក្នុងផ្នែកណាមួយបានដែលគេចាប់អារម្មណ៍ឬក៏គេ នឹងមិនគិតថាមានតំលៃក្នុងការនិយាយជាមួយអ្នកអំពីការបារម្មណ៍របស់គេ។ ក្នុងករណីរបស់យើងការវិនិយោគរបស់យើងក្នុងវិស័យទាំងនេះ ដែលជាតម្រូវការដ៏ឆ្លាតវៃ តែមិនមែនជាអទិភាពចំបងជាគ្រឹសំរាប់ បន្តទៅជំហានបន្ទាប់ទៀតនៃការវិនិយោគ។

## ជំហ៊ានទី ២ ការឆ្លើយតបចំពោះតម្រូវការដែលគេចាប់អារម្មណ៍

បន្ទាប់ពីធ្វើការជាមួយម៉ាណូបូអស់រយះពេលជាច្រើនខែមក ជនជាតិម៉ាណូបូ បានមកសុំអោយជួយក្នុងការចិញ្ចឹងត្រីទីឡាប់យ៉ា។អត់មានការបង្រៀនពីការផលិតត្រីទីឡាប់យ៉ាទេនៅក្នុងតំបន់ហើយអក្សសាស្ត្រដែលអាចមានគឺសរសេរជាភាសាអង់គ្លេស ដែលជនជាតិនេះមិនមានឱកាសរៀនឡើយ។ ដូច្នេះយើងបានប្រមូលព័ត៌មានក្នុងការចិញ្ចឹងត្រីនេះ ដោយជ្រើសរើសវិធីមួយដែលសមរម្យសំរាប់ស្ថានភាពជនជាតិម៉ាណូបូ។យើងបានបង្រៀនវិធីសាស្ត្រដល់អ្នកណាដែលចាប់អារម្មណ៍។ ច្រើនខែក្រោយមក មនុស្សពីភូមិអ្នកដែលមកសួរនេះបានសុំអោយជួយក្នុងការចាប់ផ្តើមផលិតស្រូវតាមប្រព័ន្ធធារាសាស្ត្រ។



*ពីឆ្វេងទៅស្តាំ (១) កសិដ្ឋានដែលពេលនេះនៅឆ្ងាយពីភូមិ ហើយនឹងព្រៃ ដែលពីបាករក ដូច្នេះ មេគ នីដានិងមែលបានបង្រៀនការធ្វើសួនដំណាំដលក្រុមស្ត្រី (២) ស្រូវដាំគឺជាដំណាំសំខាន់របសជនជាតិម៉ាណូបូ (៣) ជនជាតិម៉ាណូបូទទួលយកការធ្វើស្រែដែលមានាការស្រោចស្រព។*

យើងពេលនេះកំពុងឆ្លើយតបទៅនឹងតម្រូវការ តែអាត្រាសម្របខ្លួន គឺមានកំរិតទាបណាស់ យើងបានធ្វើតាមគោលលទ្ធិនៃការអភិវឌ្ឍន៍សហគមន៍ដែលបង្ហាញថាល្អ ដែលគំរោងគួរត្រូវបានធ្វើជាម្ចាស់និងដំណើរការដោយសហគមន៍ ទោះជាយ៉ាងណាក៏ដោយគំរោងដែលសហគមន៍ជាម្ចាស់បានបញ្ចប់ទៅដោយការនៅសល់មនុស្សតែពីរបីនាក់ក្នុងការធ្វើការទាំងអស់ដោយអ្នកដទៃចាំយកតែផល។ មនុស្សពីរបីនាក់បានសម្របខ្លួនយកការអនុវត្តន៍នេះហើយបានប្រើពួកវាក្នុងវិធីតូចរក្នុងកសិដ្ឋានរបស់គេ តែវាហាក់ដូចជាការខិតខំប្រឹងប្រែងរបស់យើងបានផលតែបន្តិចបន្តួចប៉ុណ្ណោះ។ យើងបានដឹងច្បាស់ថាទោះបីជាយើងអោយតំលៃក្នុងការធ្វើការជាមួយមនុស្សនិងចង់ធ្វើការជាមួយ គ្រាបពូជវប្បធម៌របស់គេក៏យើងនៅតែខ្វះលទ្ធភាពក្នុងការមើលថាគ្រាប់ពូជនេះជាអ្វីដែរ។

## ជំហ៊ានទី៣ ការធ្វើការជាមួយនឹងគ្រាប់ពូជ

យើងបានចាកចេញពីម៉ាណូបូរយះពេល៣ឆ្នាំ (១៩៨៦ដល់ ១៩៨៩) សំរាប់ការសិក្សាថែមទៀត។ អំឡុងពេលនេះ យើងបានចាប់ផ្តើមដំណើរការរៀនសូត្រពីរបៀបមើល គ្រាប់ពូជតាមបែបវប្បធម៌ដោយការចាប់យកកម្មសិក្សាមួយនៅក្នុងផ្នែកនរវិទ្យាវប្បធម៌។ ពេលត្រឡប់មកភីលីពីនវិញ សមាគមព្រះវិហារជនជាតិម៉ាណូបូនេះបានសុំអោយយើងជួយជនជាតិគេទាំងមូលអោយរៀនពីបច្ចេកទេសកសិកម្មថ្មី។ ពេលនេះ មុនពេលចាប់ផ្តើមការខិតខំថ្មីមួយទៀត យើងចំណាយពេល១ឆ្នាំ ក្នុងការអង្កេតពីវប្បធម៌ យើងរកឃើញថាជនជាតិនេះជាញឹកញ៉ាប់ធ្វើការរួមគ្នា ភាពជាម្ចាស់ ដែលរាប់ទាំង ការគ្រប់គ្រងទៅលើអ្វីដែលគេចង់ដាំឬសាងសង់ឬទិញ គឺមានភាពឯកជនខ្ពស់មែនទែន។វាអត់មានវិមជ្ឈការដែលមាននិរន្តរភាពណាមួយទេនៅក្នុងវប្បធម៌។ យើងដឹងច្បាស់ថា ការខិតខំណាមួយក្នុងការបង្រៀនបច្ចេកទេសថ្មីផ្នែកកសិកម្មត្រូវគិតគូដល់។

ក្នុងការស្នើរសុំរបស់ខ្ញុំ អ្នកដឹកនាំសមាគមបានជ្រើសរើសបុរសជាច្រើននាក់ដែលខ្ញុំបានបង្រៀនជាភ្នាក់ងារបន្តរ ពួកគេក៏បានកំណត់ស្រះត្រីហើយនិងស្រូវធារាសាស្រ្តថាជាបច្ចេកទេសដ៏សំខាន់បំផុតសំរាប់តំបន់ដាច់ស្រយាលនេះ ការធ្វើការរួមគ្នា ភ្នាក់ងារចែកចាយបន្តនេះនិងខ្ញុំបានផលិលសំភារះបណ្តុះបណ្តាលនិពន្ធជាភាសាម៉ាណូបូ ដែលក្រោយមកគេយកមកបង្រៀនបច្ចេកទេសថ្មី

ក្នុងភូមិរបស់គេ។ យើងបានសំរេចចិត្តប្រើយុទ្ធសាស្ត្រវិមជ្ឈការ ដែលអត់មានរចនាសម្ព័ន្ធគ្រប់គ្រងតាមថ្នាក់និងនិងមិនមានជំនួយពីខាងក្នុងនិងខាងក្រៅតំបន់ឡើយ។ ពេលនេះដោយការធ្វើការជាមួយគ្រាប់ពូជវប្បធម៌ ស្រូវលើកក្លឹកក៏រីករាលដាលដល់ទៅ៨ភូមិក្នុងរយះពេល៨ឆ្នាំខណះស្រះត្រីរីកដល់ទៅ ១៥ ភូមិក្នុងពេល៧ឆ្នាំ។

## ជំហ៊ានទី៤ ការអង្កេតមើលទាំងអស់គ្នា

ខណះពេលយើងសប្បាយចិត្តក្នុងការមើលឃើញជនជាតិម៉ាណូបូ កំពុងទទួលបានផលពីបច្ចេកទេសដ៏មានបានផលមួយចំនួន យើងក៏មានការខកចិត្តដែលបច្ចេកទេសនេះនៅតែប្រើដោយភាគទាក់ទងតិចតួចនៃប្រជាជន ទោះបីជាការពិតដែលថា វាជាបច្ចេកទេសដែលជនជាតិម៉ាណូបូពិតជាត្រូវការអោយជួយក្នុងការរៀនសូត្រ។ ការពិភាក្សាជាមួយភ្នាក់ងារចែកចាយបន្តរបស់ជនជាតិម៉ាណូបូ បានបង្ហាញថាស្ថានភាពខ្លះដែលជាតំបន់ខ្ពស់ ដែលគេធ្វើជាស្រះត្រីនិងស្រូវស្រោចស្រពដោយទឹក គឺមិនគួរអនុវត្តន៍និងមិនត្រឹមត្រូវនៅកន្លែងខ្លះឡើយ។

SALT បានកាត់ការសឹករិចរិលជានិងបង្កើនទិន្នផលជាច្រើន តែតំលៃនៃគ្រាប់ពូជមានតំលៃថ្លៃសំរាប់ចំណូលរបស់ជនជាតិម៉ាណូបូនេះ។ វាទំនងជាកើតមានថា ត្រូវការយុទ្ធសាស្ត្រផ្សេងទៀត។ ដូច្នេះគួបផ្សំជាមួយនឹងភ្នាក់ងារផ្សព្វផ្សាយបន្តរ ខ្ញុំបានទៅមើលភូមិមួយដែលគេរស់នៅនិងធ្វើការ ហើយសួរគេថាតើគេគិតថាសកម្មភាពអ្វីដែលល្អហើយមានភាពប្រាកដប្រជា។ យើងរកឃើញថា នៅក្នុងភូមិនីមួយៗ ប្រជាជនចាប់អារម្មណ៍លើការដាំឈើហូបផ្លែ។ ខ្ញុំមានមន្ទិលសង្ស័យ ខណះដែលឈើហូបផ្លែត្រូវបានហាមឃាតនៅក្នុងប្រទេសភីលីពីន ជនជាតិម៉ាណូបូភាគច្រើនរស់នៅឆ្ងាយពីផ្លូវ ហើយផ្លូវភាគច្រើនមិនអាចឆ្លងកាត់បាន។ ទោះជាយ៉ាងណាក៏ដោយ កសិករតាមពិតគេអាចដឹកផ្លែឈើទៅឯផ្លូវ (ហើយ បើត្រូវការ គឺអាចដឹកទៅដល់ទីផ្សារតែម្តង) ដោយប្រើសត្វដឹក ឬប្រើខ្នងរបស់គេតែម្តង។

ភ្នាក់ងារផ្សព្វផ្សាយបន្តរនិងខ្ញុំបានរកមើលធនធានសេដ្ឋកិច្ចនៃគ្រាប់ពូជឈើហូបផ្លែ ហើយចុងបញ្ចប់យើងរកឃើញថាយើងអាចទទួលបានពួកវានៅក្នុងតំលៃសមរម្យតាមរយះការិយាល័យ កសិកម្មក្នុងសាលាក្រុង។ យើងបានទិញជាក្រុម តែកសិករនីមួយៗបានទិញនិងចំណាយនូវអ្វីដែលគេចង់បាននៅលើដីរបស់គេ។ ឆ្នាំដំបូងកសិករ១៥នាក់ ពី៨ភូមិបានទិញ២១០ដើម។ ឆ្នាំទី២ ១៨៤គ្រួសារក្នុង១៨ភូមិបានទិញ១៩៩៩ដើម។ ដើមឈើជាច្រើនបានងាប់ដោយសារតែគ្រោះរាំងស្ងួត តែខ្លះបានរស់។ នៅពេលដែលខ្ញុំបានទៅមើលចុងក្រោយនៅឆ្នាំ២០០៦ កសិករជាច្រើនបានទាញផលប្រយោជន៍ពីផ្លែឈើ។ គេបញ្ជាក់ថា គេមានការលើកទឹកចិត្តដែលគេអាច ផ្លាស់ទៅរកការផលិតផ្នែកហិរញ្ញវត្ថុពីកសិកម្ម។ បើខ្ញុំធ្វើតាមគោលគំនិតរបស់ខ្ញុំ ជាជាងការអនុញ្ញាតិអោយសហគមន៍ធ្វើការសំរេចចិត្តនូវអ្វីដែលគេចង់ដាក់ការខិតខំរបស់គេ នោះឈើទាំងនេះប្រាកដជាមិនបានដាំឡើយ។

## សង្ខេបពីប្រវត្តិ

តាមរយះដំណើរការការងារជាមួយជនជាតិម៉ាណូបូ យើងបន្តស្វែងរកវិធីសំរាប់ពួកគេអោយមានការចូលរួមកាន់តែច្រើនឡើងក្នុងការកំណត់រូបរាងសហគមន៍របស់គេអោយកាន់តែប្រសើរឡើង។ ពីដំបូង យើងត្រឹមតែអាចបង្រៀនពីអ្វីដែលមានប្រយោជន៍សំរាប់យើង។ ការនេះមានភាពតិចតួច

ណាស់ចំពោះ ការអេះអោយចំកន្លែងរមាស់ តែវាបង្កើតអោយមានសមត្ថភាពនិងការព្រួយបារម្ភណ៍របស់យើង ហើយនាំអោយជនជាតិម៉ាណូបូសុំជំនួយក្នុងការរៀនសូត្របច្ចេកទេសថ្មី ដែលគេចាប់អារម្មណ៍មែនទែន។ នោះនាំឆ្ពោះទៅរកដំណាក់កាលទីពីរនៃការងារ ការសំរេចបានគោលដៅដែលមនុស្សជាច្រើនគិតពិចារណាថាសំខាន់ តែវាមានកំណត់ថាគេអាចប្រើប្រាស់បានប៉ុន្មា។ ជំហ៊ានចុងក្រោយគឺការលើកទឹកចិត្តសហាគមន៍អោយចេះកំណត់ ជាមួយគ្នា នូវអ្វីដែលគេជឿជាជាក់ ថាអាចនឹងផ្តល់អោយនូវលទ្ធផលខ្ពស់សំរាប់ការវិនិយោគរបស់គេ (ទាំងពលកម្មនិងទុន)។ ទាំងមូលនេះ ដំណើរការគឺផ្អែកទៅលើការគោរពពួកគេ និងទៅលើការគោរពយើងដែរ ដោយការធ្វើការជាប្រចាំឆ្ពោះទៅរកការបំពេញតួនាទីនៃធនធាននិងអ្នកបង្រៀនដោយមិនមានការគ្រប់គ្រង។

## ការសន្និដ្ឋាន

នៅពេលដែលវិធីសាស្ត្រតាមបែបចូលរួមគឺសមរម្យទាក់ទងនឹងឧបករណ៍សំរាប់អ្នកអនុវត្តន៍ ពាក្យ យុទ្ធសាស្ត្រតាមបែបចូលរួម គ្របបាំងឥរិយាបថដែលជាខ្សែក្រវ៉ាត់ការងារនេះ។វាគឺជាអទិភាពសំរាប់ការងារជាមួយមនុស្សនិងសហាគមន៍របស់គេ ការលើកទឹកចិត្តពួកគេអោយថែរក្សាគ្នាទៅវិញទៅមកហើយធ្វើការឆ្ពោះទៅរកគោលដៅ ហើយជាធនធាន និងជាការបង្រៀននៅពេលដែលខំប្រឹងទុកការគ្រប់គ្រងអោយទៅសហាគមន៍។ ក្នុងនាមជាធនធានអាចមានន័យថាជាការផ្តល់អោយនូវការទទួលបានព័ត៌មាន ក្នុងភាសាមួយទៀត។ វាអាចជាមានន័យថាជួយមនុស្សអោយរៀនបានពីរបៀបទទួលបានព័ត៌មាននោះដោយខ្លួនឯង តាមរយះផ្លូវមួយទៀតជាជាងអក្សរសាស្ត្រដែលបានបោះពុម្ពហើយ។ វាអាចជាមានន័យថានាំគេក្នុងបច្ចេកទេស ដែលអាចជួយពួកគេអោយឃើញព័ត៌មានអំពីសហាគមន៍របស់គេដែលគេមើលថៃ ហើយនិងដោះស្រាយជាមួយភាពស្មុគ្រស្មាញជាមួយព័ត៌មាននេះ។តែជាគ្រឹះនៃឧបករណ៍ទាំងនេះគឺអាកប្បកិរិយាដែលមនុស្សខ្លួនឯងដែលត្រូវសាកល្បង ហើយថាយើងជាដៃគូដ៏សមញ្ញមួយ។

## ឯកសាយោង

ប្រ្ហេសឺដូក្លាស ២០០៧ អ្នកកាត់ឈើ អ្នកតាំងទីលំនៅ និងជនជាតិដើម ក្នុងព្រៃភ្នំ នៅប្រទេសភីលីពីន។ ការវិវត្តន៍អង្គការសង្គមជនជាតិភាគតិច ក្នុងការឆ្លើយតបទៅនឹងការឈ្លានពានផ្នែកបរិស្ថាន។ បណ្ឌិតផ្នែកការអធិប្បាយ សកលវិទ្យាល័យហ្វ្លរីដា

Sanchez, Pedro A. 1976. Properties and Management of Soils in the Tropics. New York: John Wiley & Sons. សាន់ឆេស ភេត្រូ ១៩៧៦ ទ្រព្យនិងការគ្រប់គ្រងដីនៅតំបន់ត្រូពិក ញូយ៉ក ចន វិលី និងសាន់

## ការផ្តល់អនុសាសន៍អោយអាន

Lingenfelter, Sherwood G. 1992. Grand Rapids: Baker Book House.

វប្បធម៌ដែលមានការផ្លាស់ប្រែ ការប្រឈមរបស់បេសកកម្មគ្រីស្ទបរិស័ទ  នេះជាសៀវភៅដែលគួរអោយចង់អានមានទ្រឹស្តីគ្រប់គ្រាន់ ដែលជួយអោយយល់ពីរបៀបសង្គមគិតនិងធ្វើការង

ភ្នាក់ងារសំរាប់ការផ្លាស់ប្តូ ការនែនាំសំរាប់បេសកកម្មវប្បធម៌ចំរុះ សៀវភៅនេះពង្រីកអោយមានការផ្លាស់ប្រែជាមួយនឹងការអនុវត្តន៍ជាច្រើន វាថែមទាំងផ្តល់សំណួរស្រាវជ្រាវ ដើម្បីនែនាអ្នកក្នុងការអង្កេតទិដ្ឋភាពនីមួយៗនៃវប្បធម៌។

Myers, Bryant L. 2006. ការដើរជាមួយអ្នកក្រ គោលការណ៍និងការអនុវត្តន៍នៃការអភវឌ្ឍន៍តាមបែបផ្លាស់ប្រែ. នេះអាចជាសៀវភៅដែលល្អបំផុត ស្តីពីការអភិវឌ្ឍន៍សហគមន៍ដែលខ្ញុំមិនធ្លាប់ឃើញ។ វាចាក់ឫសទៅលើការងាយុទ្ធសាស្ត្រតាមបែបចូលរួម។ អ្នកអានអាចំណាយពេលទាំងប្រវត្តិសាស្ត្រនៃយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ បង្ហាញពីភាពខ្លាំងនិងចំណុចខ្សោយនីមួយៗ ហើយផ្តល់នូវការណែនាំក្នុងការប្រើប្រាស់វិធីសាស្ត្រដែលមានប្រយោជន៍ជាច្រើន។